# រាជបណ្ឌិត្យសភាកម្ពុជា
## វិទ្យាស្ថានវប្បធម៌ និង វិចិត្រសិល្បៈ

អត្ថបទស្រាវជ្រាវ

ស្តីពី

# «របកគំហើញថ្មី ស្ថានីយឡផលិតក្បាលភាជន៍សម័យដូចគ្នានឹងស្ថានីយជើងឯក»




ដោយ៖ កញ្ញា តាកេត ស័កដា

ខែមីនា ឆ្នាំ២០១៩

# «របកគំហើញថ្មី
# ស្ថានីយឡផលិតកុលាលភាជន៍សម័យដូចគ្នានឹងស្ថានីយជើងឯក»

អត្ថបទស្រាវជ្រាវដោយ៖ កញ្ញា តាកេត សីកដា
**វិទ្យាស្ថានវប្បធម៌ និង វិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា**

នៅក្នុងភូមិស្វាយពោធិ ឃុំព្រះប្រសប់ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាមមានព្រំប្រទល់ជាប់នឹងខេត្តកណ្តាល ដែលជាតំបន់ទំនាបនៃដងទន្លេមេគង្គលើ មានឡដុតកុលាលភាជន៍មួយចំនួនដែលនៅរក្សារូបរាងជាទួលខ្ពស់កម្ពស់ប្រមាណជាង២ម៉ែត្រ។ នៅលើទួលឡនេះមានបំណែកកុលាលភាជន៍ដែលយើងអាចស្គាល់បានថាជាប្រភេទកុលាលភាជន៍ផលិតនៅស្ថានីយជើងឯក។ ប្រសិនបើយើងមិនបានឃើញទួលឡទេ នោះយើងនឹងសន្និដ្ឋានថាកុលាលភាជន៍ទាំងនេះយកមកពីស្ថានីយជើងឯក តាមរយៈការដឹកជញ្ជូនតាមផ្លូវទឹក។

អ្វីដែលយើងបានរកឃើញ ជាភស្តុតាងបង្ហាញថា ទីតាំងនេះគឺជាស្ថានីយផលិតកុលាលភាជន៍មួយដែរ ប៉ុន្តែយកលំនាំ និងរចនាបថតាមកុលាលភាជន៍ដែលផលិតនៅស្ថានីយជើងឯក។ សូមបញ្ជាក់ថា លោកបណ្ឌិត ផុន កសិកា បានសិក្សាស្រាវជ្រាវនៅស្ថានីយជើងឯកតាំងពីឆ្នាំ២០០២ និងបានបញ្ចប់សញ្ញាបត្រថ្នាក់បណ្ឌិត ដោយសរសេរនិក្ខេបបទអំពីកុលាលភាជន៍និងឡនៅស្ថានីយជើងឯក។ លទ្ធផលស្រាវជ្រាវបានបង្ហាញថា នៅស្ថានីយជើងឯកមានឡផលិតកុលាលភាជន៍៦៩ និងឡកុលាលភាជន៍រឹងមានអាយុកាលនៅសម័យអង្គរ (សតវត្សទី៩-១៣)។

កុលាលភាជន៍ដែលប្រមូលបានពីឡភូមិស្វាយពោធិ ឃុំព្រះប្រសប់ ជាប្រភេទកុលាលភាជន៍រឹង កំណល់ទ្រកុលាលភាជន៍និងមានក្បឿងផងដែរ។ ក្បឿងដែលរកឃើញនេះគឺជាប្រភេទក្បឿងរងស្បូវដែលមានរចនាដោយរូបចម្លាក់អប្សរាក្នុងកាយវិការរាំ និងមានក្បាច់លម្អសក់ជាកំពូលបីខ្ពស់ទៅលើ។ ចម្លាក់អប្សរាដែលឆ្លាក់លើក្បឿងរងស្បូវដែលមានក្បាច់ចម្លាក់អប្សរានៅពីលើបែបនេះមិនមានជួបប្រទេះនៅតាមស្ថានីយបុរាណណាមួយឡើយ ទោះបីនៅតំបន់អង្គរដែលជារាជធានីខ្មែរដ៏ធំនិងល្បីល្បាញ ក៏ពុំដែលប្រទេះឃើញក្បឿងរងស្បូវបែបនេះដែរ។

ស្ថានីយបុរាណដែលទើបរកឃើញនេះមិនទាន់មានអ្នកស្រាវជ្រាវខ្មែរ ឬបរទេសណាបានសិក្សាស្រាវជ្រាវនៅឡើយទេ។ ស្ថានីយនេះពិតជាមានសក្តានុពលក្នុងការសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យា ប្រវត្តិសាស្ត្រ និងភូមិសាស្ត្រដែលរាជបណ្ឌិត្យសភាកម្ពុជា អាចនឹងធ្វើការសិក្សាស្រាវជ្រាវទៅថ្ងៃអនាគតបានដោយជោគជ័យទៀតផង។ ពិសេសទៅទៀត ប្រសិនបើយើងមិនបានសិក្សាស្រាវជ្រាវពីស្ថានីយនេះឱ្យបានទាប់រហ័សនោះទេ ការបំផ្លាញស្ថានីយនឹងអាចកើតឡើង ហើយនឹងឈានដល់ការបាត់បង់តឹកតាងប្រវត្តិសាស្ត្រដ៏សំខាន់នេះ ពីព្រោះការបំផ្លាញស្ថានីយបុរាណនាពេលបច្ចុប្បន្នធ្វើឡើងតាមរយៈការប្រើម៉ាស៊ីនឈូស ឬប្រើអេស្កាកាប់ កាយ ឈូស តែក្នុងរយៈខ្លីបំផុត ស្ថានីយបុរាណនឹងរលាយបាត់បង់។



ផែនទីទីតាំងឡស្ថិតក្នុងភូមិស្វាយពោធិ ឃុំព្រះប្រសប់ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម



ក្បឿងរងស្បូវមានក្បាច់លម្អរូបអប្សរា











កុលាលភាជន៍រកឃើញនៅទីតាំងឡកុលាលភាជន៍ក្នុងភូមិស្វាយពោធិ ឃុំព្រះប្រសប់ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម



ប្រភេទកំណល់ប្រើសម្រាប់កល់កុលាលភាជន៍ក្នុងពេលដុតក្នុងឡ
(រកឃើញនៅទីតាំងឡកុលាលភាជន៍ក្នុងភូមិស្វាយពោធិ ឃុំព្រះប្រសប់ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម)